# ដំណើរការនៃការធ្វើសវនាការ
# យុត្តិធម៌សម្រាប់អ្នកប្រើប្រាស់ដែលមាន
# អាយុ ៣ ឆ្នាំ ឬ ច្រើនជាងបីឆ្នាំ

# DDS

## ក្រសួងផ្តល់សេវាកម្មដល់ការអភិវឌ្ឍន៍

ខែ វិច្ឆិកា ឆ្នាំ ២០០១

# តារាងមាតិកា


តើដំណើរការនៃការធ្វើសវនាការយុត្តិធម៌ជាអ្វី ? .......... 1

តើមានមធ្យោបាយណាមួយ ដើម្បីដោះស្រាយដោយមិនចាំបាច់មានសវនាការយុត្តិធម៌ដែរឬទេ ? .......... 2

តើគម្រោងនៃពេលវេលាចំពោះការចាប់ផ្តើមដំណើរការនៃការធ្វើសវនាការយុត្តិធម៌មានយ៉ាងដូចម្តេចខ្លះ ? .......... 2

តើមានអ្វីកើតឡើងនៅពេលដែលខ្ញុំរៀបចំដាក់សំណើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌ ? .......... 2

តើខ្ញុំមានសិទ្ធិអ្វីខ្លះនៅរាល់ដំណាក់កាលនៃដំណើរការធ្វើសវនាការយុត្តិធម៌និមួយៗ ? .......... 3

តើខ្ញុំអាចទទួលបានការជួយជាមួយនឹងដំណើរការនេះដោយរបៀបណា ? .......... 3

តើការជួបមិនមែនជាផ្លូវការដោយស្ម័គ្រចិត្ត ត្រូវបានគេគ្រោងធ្វើឡើងដោយរបៀបណា ? .......... 3

តើមានអ្វីកើតឡើងនៅក្នុងការជួបមិនមែនជាផ្លូវការដោយស្ម័គ្រចិត្ត ? .......... 4

តើខ្ញុំនឹងត្រូវបានគេផ្តល់ដំណឹងពីការសម្រេចទៅលើការជួបមិនមែនជាផ្លូវការរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ដោយវិធីណា និង នៅពេលណា ? .......... 4

តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំមិនយល់ព្រមចំពោះសេចក្តីសម្រេចទៅលើការជួបមិនមែនជាផ្លូវការរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ? .......... 5

តើការសម្របសម្រួលត្រូវបានគ្រោងធ្វើឡើងដោយរបៀបណា ? .......... 5

តើត្រូវធ្វើដូចម្តេច ប្រសិនបើខ្ញុំត្រូវការឱ្យគេគ្រោងធ្វើការសម្របសម្រួលសារជាថ្មី ? .......... 5

តើការសម្របសម្រួលមានលក្ខណៈយ៉ាងដូចម្តេច ? .......... 5

តើមានអ្វីកើតឡើង ប្រសិនបើការសម្របសម្រួល មិនអាចដោះស្រាយបញ្ហាបាន? .......... 6

តើការធ្វើសវនាការយុត្តិធម៌ ត្រូវបានគ្រោងធ្វើឡើងដោយរបៀបណា ? .......... 6

តើត្រូវធ្វើដូចម្តេច .......... 6

តើសវនាការយុត្តិធម៌មានលក្ខណៈយ៉ាងដូចម្តេច ? .......... 7

តើខ្ញុំនឹងត្រូវបានគេផ្តល់ដំណឹងពីសេចក្តីសម្រេចនៃការធ្វើសវនាការយុត្តិធម៌ដោយវិធីណា និង នៅពេលណា ? .......... 7

តើច្បាប់ និង បទបញ្ញត្តិអ្វីខ្លះ ដែលមាននៅក្នុងនីតិវិធីនៃការធ្វើសវនាការយុត្តិធម៌ ? .......... 8

## តើដំណើរការនៃការធ្វើសវនាការយុត្តិធមិជាអ្វី ?

ដំណើរការនៃការធ្វើសវនាការយុត្តិធមិ ដែលបានលើកយកមកពណ៌នាក្នុងកូនសៀវភៅផ្សព្វផ្សាយពតិមាននេះ គឺជាដំណើរការដើម្បីដោះស្រាយរាល់ការមិនព្រមព្រៀងគ្នារវាងមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬមជ្ឈមណ្ឌលប្រចាំតំបន់ ជាមួយនឹងអ្នកប្រើប្រាស់ ឬអ្នកដាក់ពាក្យសុំ ដែលមាន**អាយុបីឆ្នាំ ឬ ច្រើនជាងបីឆ្នាំ** ។ ចំពោះការមិនព្រមព្រៀងគ្នាណា ដែលទាក់ទងនឹងអ្នកប្រើប្រាស់ ឬ អ្នកដាក់ពាក្យសុំទាំងឡាយ ណាដែលមាន**អាយុក្រោម ៣ ឆ្នាំ** សូមមើលឯកសារដែលមានឈ្មោះថា**សិទ្ធិរបស់ឪពុកម្តាយនៅក្នុងការចាប់ផ្តើមជាលើកដំបូង** (Parent’s Rights in Early Start) ដែលមាននៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ។

ក្រោមដំណើរការនៃការធ្វើសវនាការយុត្តិធមិនេះ ការមិនព្រមព្រៀងគ្នាអាចនឹងអំពីសេវាកម្មផ្សេងៗ ភាពមានសិទ្ធិស្របច្បាប់ ឬ ការសម្រេច ឬ ចំណាត់ការរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ដែលអ្នកមិនព្រមព្រៀងជាមួយ ។ ដំណើរការ នៃការធ្វើសវនាការយុត្តិធមិរួមមានការជួបមិនមែនជាផ្លូវការដោយស្ម័គ្រចិត្ត ការសម្របសម្រួល និង សវនាការយុត្តិធមិ ។

ប្រសិនបើអ្នកមានការជួបមិនមែនជាផ្លូវការដោយស្ម័គ្រចិត្ត វាគឺជាការជួបជុំមួយដែលធ្វើឡើងដោយនាយកមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ឬ អ្នករៀបចំរបស់គាត់ជាមួយនឹងអ្នក ហើយនិងអ្នកតំណាងស្របច្បាប់របស់អ្នក។ គោលបំណងនៃការជួបមិនមែនជា ផ្លូវការដោយស្ម័គ្រចិត្តនេះ គឺដើម្បីដោះស្រាយបញ្ហាផ្សេងៗនៃបណ្តឹង ។ អ្នក ឬ អ្នកតំណាងស្របច្បាប់របស់អ្នកអាចនឹងច្រានចោលការជួបមិនមែន ជាផ្លូវការនេះបាន ។

ប្រសិនបើអ្នក ឬ អ្នកតំណាងស្របច្បាប់របស់អ្នកច្រានចោលការជួបមិនមែនជាផ្លូវការនេះ ឬ មិនពេញចិត្តនឹងការសម្រេចរបស់ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ក្រោយពេលជួបមិនមែនជាផ្លូវការរួច ហើយអ្នកមិនទាន់បានស្នើសុំការសម្របសម្រួល នោះ អ្នកអាចនឹងស្នើសុំការសម្របសម្រួល ឬ បន្តដោយផ្ទាល់ទៅសវនាការយុត្តិធមិ ។

ប្រសិនបើការសម្របសម្រួលត្រូវបានស្នើសុំ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ អាចនឹងទទួលយក ឬ ច្រានចោល សំណើនោះបាន ។ ប្រសិនបើទទួលយក នោះការសម្របសម្រួលនឹងត្រូវធ្វើឡើងតាមលក្ខណៈធម្មតាមួយ ដោយអ្នកសម្របសម្រួលដែលបានផ្តល់ ជូនដោយ Office of Administrative Hearings ។ អ្នក ឬ អ្នកតំណាងស្របច្បាប់របស់អ្នក ឬ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ អាចនឹងចាកចេញនៅពេលណាក៏បាន ពីការសម្របសម្រួលនោះបាន ហើយបន្តទៅសវនាការយុត្តិធមិមួយវិញ ។

ប្រសិនបើអ្នក អ្នកតំណាងស្របច្បាប់របស់អ្នក ឬ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ច្រានចោលការសម្រប សម្រួលនោះ ឬ ក៏ប្រសិនបើការសម្របសម្រួលនោះមិនបានដោះស្រាយបញ្ហាមួយ ឬ ច្រើនឱ្យពេញចិត្តអ្នក ឬ អ្នកតំណាងស្របច្បាប់របស់អ្នកនោះទេ បញ្ហានោះនឹងត្រូវបន្តទៅសវនាការយុត្តិធមិ ។

សវនាការយុត្តិធមិ គឺមានលក្ខណៈផ្លូវការជាង ហើយត្រូវបានធ្វើឡើងដោយចៅក្រមច្បាប់រដ្ឋបាល ដែលត្រូវបានជួលដោយការិយាល័យ សវនាការខាងកិច្ចការរដ្ឋបាល ។

សេចក្តីសម្រេចចុងក្រោយមួយ ត្រូវបានផ្តល់ជូន**ក្នុងរយៈពេល ៩០ ថ្ងៃ** ចាប់តាំងពីបានទទួលបែបបទស្នើសុំឱ្យមានសវនាការយុត្តិធមិ ដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ។ ចំនួនរយៈពេលកំណត់ដែលមាន ៩០ ថ្ងៃនេះ អាចនឹងត្រូវបានពន្យារ ប្រសិនបើ អ្នកស្នើសុំការសម្របសម្រួល ឬ ប្រសិនបើអ្នកស្នើសុំឱ្យមានការបន្ត ឬ ការពន្យាពេលនៃការធ្វើសវនាការ ។

សេចក្តីជូនដំណឹងពីចំណាត់ការដែលបានស្នើឡើង ដែលទទួលបានពីមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ប្រសិនបើ អាចយកមកប្រើការបាន បង្ហាញប្រាប់ថាតើអ្នកគឺសមាជិករបស់ Waiver Program ឬ មិនមែន។ ប្រសិនបើមិនបានទទួលសេចក្តីជូនដំណឹងពីចំណាត់ ការដែលបានស្នើឡើងទេនោះ អ្នកអាចទាក់ទងមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ដើម្បីកំណត់ថាតើអ្នក គឺជាសមាជិករបស់ Waiver Program ឬក៏មិនមែន ។ **សេវាកម្មទាំងអស់មិនត្រូវបានជះឥទ្ធិពលដោយការចូលរួម ឬ ការមិនចូលរួមរបស់អ្នកក្នុង Waiver Program នេះឡើយ ។ ប្រសិនបើអ្នកគឺជាសមាជិករបស់ Waiver Program**

**ហើយត្រូវបានផ្តល់ដំណឹងដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌល ប្រចាំតំបន់ ថាអ្នកលែងមានសិទ្ធិស្របច្បាប់ចំពោះការចូលរួមក្នុង Waiver Program ទេនោះ នោះសេវាកម្មទាំងអស់ដែលអ្នកមាន នឹងមិនត្រូវទទួលផលប៉ះពាល់ ពីការផ្លាស់ប្តូរនេះឡើយ ។**

### ***តើមានមធ្យោបាយណាមួយ ដើម្បីដោះស្រាយដោយមិនចាំបាច់មានសវនាការយុត្តិធម៌ដែរឬទេ ?***

ការមានគំនិតផ្សេងគ្នា ជារឿយៗអាចត្រូវដោះស្រាយបានដោយមិនចាំបាច់មានសវនាការយុត្តិធម៌ទេ ។ សូមទាក់ទងមកអ្នកតំណាង មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ អ្នកគាំទ្រសិទ្ធិរបស់អ្នកប្រើប្រាស់ គណៈគ្រប់គ្រងតំបន់ ឬ អង្គការដែលផ្តល់ការ គាំទ្រដទៃទៀត ដើម្បីទទួលបានពត៌មាន ឬ ជំនួយបន្ថែម ។

### ***តើគម្រោងនៃពេលវេលាចំពោះការចាប់ផ្តើមដំណើរការនៃការធ្វើសវនាការយុត្តិធម៌មានយ៉ាងដូចម្តេចខ្លះ ?***

បេក្ខជន អ្នកទទួលបាននូវសេវាកម្មផ្សេងៗ ឬ អ្នកតំណាងស្របច្បាប់ទាំងអស់ អាចនឹងធ្វើសំណើសុំឱ្យមានសវនាការយុត្តិធម៌បាន ។ សំណើនោះ ត្រូវធ្វើឡើងជា**លាយលក្ខណ៍អក្សរ** ហើយត្រូវរៀបចំដាក់ជូនមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ក្នុង**រយៈពេល ៣០ ថ្ងៃ** បន្ទាប់ពីការចេញសេចក្តីជូនដំណឹងពីការសម្រេច ឬ ចំណាត់ការដែលអ្នក ឬ អ្នកតំណាងស្របច្បាប់របស់អ្នកមិនទទួលយក ។សំណើនេះ ត្រូវតែមាននៅក្នុងបែបបទនៃការស្នើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌ ដែលបានប្រគល់ជូនដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌល ប្រចាំតំបន់ ។

**អ្នកអាចស្នើសុំដោយផ្ទាល់មាត់ទៅបុគ្គលិករបស់មជ្ឈមណ្ឌលប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ឱ្យមានការធ្វើសវនាការយុត្តិធម៌បាន ។ បុគ្គលិករបស់មជ្ឈមណ្ឌល នឹងផ្តល់ជូនអ្នកនូវបែបបទស្នើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌មួយ ហើយជួយអ្នកដើម្បីបំពេញបែបបទនេះ ប្រសិន បើត្រូវការ ។** សេវាកម្មផ្សេងៗដែលកំពុងតែមាន នឹងត្រូវបន្តក្នុងអំឡុងពេលនៃដំណើរការនៃការប្តឹង ប្រសិនបើសំណើសុំឱ្យមានការធ្វើសវនាការ យុត្តិធម៌ត្រូវបានគេបោះត្រាលើ ឬ ត្រូវបានទទួលដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ក្នុង**រយៈពេល ១០ ថ្ងៃ** បន្ទាប់ពី អ្នកបានទទួលនូវសេចក្តីជូនដំណឹងជាលាយលក្ខណ៍អក្សរស្តីពីការសម្រេច និង ចំណាត់ការដែលអ្នកមិនទទួលយកនោះ ។ ការបន្តផ្តល់សេវាកម្មផ្សេងៗ ក្នុងអំឡុងពេលដំណើរការនៃការធ្វើសវនាការយុត្តិធម៌ ត្រូវបានគេស្គាល់ថាជា "រយៈពេលរង់ចាំជំនួយដែលត្រូវបង់" ។

### ***តើមានអ្វីកើតឡើងនៅពេលដែលខ្ញុំរៀបចំដាក់សំណើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌ ?***

នៅពេលដែលមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ទទួលបាននូវសំណើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌របស់អ្នក ពួកគេ នឹងបញ្ជូនឱ្យអ្នក ឬ អ្នកតំណាងស្របច្បាប់របស់អ្នកនូវកូនសៀវភៅថតចម្លងស្តីពីសវនាការយុត្តិធម៌ ដែលណែនាំអ្នកអំពីសវនាការយុត្តិធម៌ ការ សម្របសម្រួល និង សិទ្ធិក្នុងការជួបមិនមែនជាផ្លូវការ ប្រសិនណាបើមិនមានឯកសារណាមួយ ត្រូវបានបញ្ជូនទៅឱ្យអ្នកដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ពីមុនទេនោះ ។ អ្នកក៏នឹងតូវបានជូនជាយោបល់អំពីកាលបរិច្ឆេទ ពេលវេលា និង ទីកន្លែងដែលស្នើឡើងចំពោះ ការជួបមិនមែនជាផ្លូវការដោយស្ម័គ្រចិត្ត ប្រសិនបើមានការជួបនេះត្រូវបានស្នើឡើងដោយអ្នក ឬ អ្នកតំណាងប្រសច្បាប់របស់អ្នក ។

ប្រសិនបើការសម្របសម្រួលត្រូវបានស្នើឡើង មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ មាន**ថ្ងៃសម្រាប់ធ្វើការចំនួន ៥ ថ្ងៃ** ចាប់តាំងពីថ្ងៃនៃការទទួលសំណើជាលាយលក្ខណ៍អក្សរចំពោះការទទួលយក និង ការច្រានចោលការសម្របសម្រួល ។ ប្រសិនបើ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ច្រានចោលការសម្របសម្រួលនោះ សេចក្តីជូនដំណឹងនឹងត្រូវផ្ញើទៅឱ្យអ្នក ឬ អ្នកតំណាង ស្របច្បាប់របស់អ្នកវិញភ្លាម ។

ដូចគ្នានេះដែរ **ក្នុងរយៈពេល ៥ ថ្ងៃ** នៃការទទួលបាននូវសំណើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌របស់អ្នក មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ នឹងបញ្ជូនទូរសារអត្ថបទថតចម្លងនៃសំណើរបស់អ្នក ទៅ Office of Administrative Hearings ប្រសិនបើការសម្របសម្រួលត្រូវបានស្នើសុំ។ បន្ទាប់ពីទទួលបាននូវសំណើសុំឱ្យមានការការធ្វើសវនាការយុត្តិធម៌របស់អ្នក ការិយាល័យសវនាការខាងរដ្ឋបាល ក៏នឹងបញ្ជូនឱ្យអ្នកនូវពត៌មាន ដែលទាក់ទងនឹងសិទ្ធិនៃការធ្វើសវនាការយុត្តិធម៌របស់អ្នកផងដែរ ។ អ្នកក៏នឹងទទួលបាននូវសេចក្តីជូនដំណឹងពីពេលវេលា ទីកន្លែង និង កាលបរិច្ឆេទនៃការធ្វើសវនាការយុត្តិធម៌ ការអាចរកបាននូវជំនួយក្នុងការគាំទ្រ ហើយនិងសិទ្ធិ និង ការទទួលខុសត្រូវនានារបស់ភាគីដែលពាក់ព័ន្ធ នឹងការធ្វើសវនាការយុត្តិធម៌នេះផងដែរ ។

ប្រសិនបើការសម្របសម្រួលត្រូវបានគេទទួលយក Office of Administrative Hearings នឹងផ្ញើផងដែរឱ្យអ្នកនូវព័ត៌មានផ្សេងៗដែលទាក់ទងនឹងសិទ្ធិក្នុងការសម្របសម្រួល ។ អ្នកក៏នឹងទទួលបាននូវសេចក្តីជូនដំណឹងពីពេលវេលា ទីកន្លែង និងកាលបរិច្ឆេទនៃការសម្របសម្រួល ការអាចរកបានជំនួយក្នុងការគាំទ្រ ហើយនិងសិទ្ធិ និង ការទទួលខុសត្រូវនានារបស់ភាគី ដែលពាក់ព័ន្ធនឹងការសម្របសម្រួលនេះ ។

## *តើខ្ញុំមានសិទ្ធិអ្វីខ្លះនៅរាល់ដំណាក់កាលនៃដំណើរការធ្វើសវនាការយុត្តិធម៌និមួយៗ?*

បេក្ខជន អ្នកទទួលបានសេវាកម្មផ្សេងៗ ឬ អ្នកតំណាងស្របច្បាប់រាល់គ្នា មានសិទ្ធិនៅរាល់ដំណាល់កាលនៃដំណើរការធ្វើសវនាការយុត្តិធម៌ នីមួយៗដូចខាងក្រោម (ការជួបមិនមែនជាផ្លូវការ ការសម្របសម្រួល ការធ្វើសវនាការយុត្តិធម៌) :

- អ្នកអាចនឹងមានបុគ្គលម្នាក់ ឬ ទីភ្នាក់ងារមួយដែលបានតែងតាំងដោយគណៈគ្រប់គ្រងផ្ទែកនៅក្នុងតំបន់ ឱ្យធ្វើជាតំណាងរបស់អ្នក ដើម្បីជួយអ្នកក្នុងដំណើរការធ្វើសវនាការយុត្តិធម៌នេះ ។
- អ្នកអាចនឹងមានវត្តមាននៅក្នុងការជួបមិនមែនជាផ្លូវការ ការសម្របសម្រួល និង នៅឯសវនាការយុត្តិធម៌ជាមួយតំណាងរបស់អ្នកទៅតាមការជ្រើសរើសរបស់អ្នក ។
- អ្នកអាចនឹងត្រូវផ្តល់នូវភស្តុតាងផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ
- អ្នកអាចនឹងប្រឈមមុខនឹង ហើយផ្ទៀងផ្ទាត់ចម្លើយសាក្សី
- អ្នកអាចនឹងបង្ហាញខ្លួនជាមួយមេធាវី ឬ តំណាងណាដែលអ្នកជ្រើសរើស
- អ្នកអាចនឹងត្រួតពិនិត្យសារឡើងវិញនូវរបាយការណ៍ ដែលមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់បានទទួលក្នុងពេលផ្តល់សេវាកម្មផ្សេងៗ និង
- អ្នកអាចនឹងស្នើឱ្យមានការផ្តល់ឱ្យនូវអ្នកបកប្រែម្នាក់ ប្រសិនបើចាំបាច់ ដោយមិនចាំបាច់ឱ្យអ្នកបង់ប្រាក់ ។

## *តើខ្ញុំអាចទទួលបានការជួយជាមួយនឹងដំណើរការនេះដោយរបៀបណា ?*

អ្នកអាចទទួលការជួយពីមិត្តភក្តិ សមាជិកគ្រួសារ អ្នកគាំទ្រ មេធាវី ឬ អ្នកណាផ្សេងទៀតដែលអ្នកជ្រើសរើស ។ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់មិនទទួលខុសត្រូវចំពោះការចំណាយទេ ប្រសិនបើអ្នកជួលមេធាវី ឬ អ្នកណាម្នាក់ផ្សេងទៀត ដើម្បីឱ្យជួយអ្នក ។ នៅពេល ដែលសំណើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌ត្រូវបានគេទទួលយក មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ត្រូវតែផ្តល់ជូនអ្នក ផងដែរនូវព័ត៌មានស្តីពីជំនួយក្នុងការគាំទ្រដែលមានដោយរួមទាំងការផ្តល់យោបល់ឱ្យទៅរកអ្នកការពារសិទ្ធិរបស់អ្នកប្រើប្រាស់ គណៈគ្រប់គ្រងតំបន់ និង អង្គការផ្តល់ការគាំទ្រផ្សេងៗទៀត ។

## *តើការជួបមិនមែនជាផ្លូវការដោយស្ម័គ្រចិត្ត ត្រូវបានគេគ្រោងធ្វើឡើងដោយរបៀបណា ?*

នៅពេលដែលមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ទទួលបាននូវបែបបទនៃការស្នើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ នឹងផ្តល់ដំណឹងដល់អ្នក និង តំណាងស្របច្បាប់របស់អ្នកជាលាយលក្ខណ៍អក្សរអំពីសិទ្ធិ របស់អ្នកក្នុងការធ្វើសវនាការយុត្តិធម៌ភ្លាម ប្រសិនបើពួកគេមិនទាន់បានធ្វើបែបនេះជាមួយនឹងសេចក្តីជូនដំណឹងស្តីពីចំណាត់ការ ដែលស្នើឡើង នោះទេ។ លើសពីនេះទៅទៀត អ្នក ឬ តំណាងស្របច្បាប់របស់អ្នក នឹងត្រូវបានណែនាំពីកាលបរិច្ឆេទ ពេលវេលា និង ទីកន្លែងដែលបានស្នើឡើង ចំពោះការជួបមិនមែនជាផ្លូវការដោយស្ម័គ្រចិត្តមួយ ប្រសិនបើបានស្នើឡើងដោយអ្នក ឬ តំណាងស្របច្បាប់របស់អ្នក។ អ្នក ឬ តំណាងស្របច្បាប់របស់អ្នក អាចនឹងត្រូវត្រួតពិនិត្យឡើងវិញនូវរបាយការណ៍មុនពេលមានការជួបមិនមែនជាផ្លូវការ។ ការជួបមិនមែនជាផ្លូវការដោយស្ម័គ្រចិត្ត នឹងត្រូវបានធ្វើឡើងក្នុង**រយៈពេល ១០ ថ្ងៃ** ចាប់ពីថ្ងៃដែលបែបបទនៃការស្នើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌ ត្រូវបានទទួលដោយ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ

មជ្ឈមណ្ឌលប្រចាំតំបន់ ។

### ***តើមានអ្វីកើតឡើងនៅក្នុងការជួបមិនមែនជាផ្លូវការដោយស្ម័គ្រចិត្ត ?***

នាយកមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ឬ អ្នករៀបចំរបស់គាត់ នឹងរៀបចំការជួបមិនមែនជាផ្លូវការនេះ ។ ការជួប មិនមែនជាផ្លូវការនឹងត្រូវបានធ្វើឡើងនៅពេលវេលា និង កន្លែងណាមួយដែលស្រួលយ៉ាងសមរម្យដល់អ្នក និង តំណាងស្របច្បាប់របស់អ្នក ។ ការជួបមិនមែនជាផ្លូវការនោះ នឹងប្រើភាសាអង់គ្លេស ប៉ុន្តែមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ន ឹងផ្តល់ជូននូវអ្នកបកប្រែម្នាក់ ប្រសិនបើអ្នកត្រូវការ ហើយប្រសិនបើត្រូវបានស្នើសុំជាមុន ។ អ្នក ឬ អ្នកតំណាងរបស់អ្នកអាចនឹងត្រូវនិយាយរៀបរាប់ពីបញ្ហាទាំងឡាយ ពីការពិតទាំងឡាយ និង ហេតុផលទាំងឡាយចំពោះបណ្តឹងតវ៉ារបស់អ្នក ។ អ្នកអាចនឹងត្រូវប្រឈមមុខ និងផ្ទៀងផ្ទាត់ចម្លើយសាក្សី ។

### ***តើខ្ញុំនឹងត្រូវបានគេផ្តល់ដំណឹងពីការសម្រេចទៅលើការជួបមិនមែនជាផ្លូវការរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ដោយវិធីណា និង នៅពេលណា ?***

**ក្នុងរយៈពេលធ្វើការចំនួន ៥ ថ្ងៃ** នៃការជួបមិនមែនជាផ្លូវការនោះ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ នឹងចេញ សេចក្តីសម្រេចចិត្តជាលាយលក្ខណ៍អក្សរដល់អ្នក និង អ្នកតំណាងស្របច្បាប់របស់អ្នក ។ សេចក្តីសម្រេចនោះនឹង :

- កំណត់នូវបញ្ហាទាំងឡាយដែលបានលើកឡើង
- គ្រប់គ្រងលើបញ្ហាដែលបានកំណត់
- លើកឡើងនូវការពិតទាំងឡាយដែលជួយគាំទ្រការគ្រប់គ្រងនិមួយៗ
- កំណត់នូវច្បាប់ បទបញ្ញត្តិ និង គោលការណ៍ដែលការគ្រប់គ្រងនោះត្រូវបានផ្អែកលើ ហើយ
- ពន្យល់ពីនីតិវិធីចំពោះការប្តឹងតវ៉ាទៅលើសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ។

ប្រសិនបើអ្នក ឬ តំណាងស្របច្បាប់របស់អ្នក ពេញចិត្តនឹងសេចក្តីសម្រេចរបស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ បន្ទាប់ពីការជួបមិនមែនជាផ្លូវការមួយ ហើយអ្នកលែងប្រាថ្នាបន្តទៅការធ្វើសវនាការទៀតទេនោះ សូមបំពេញបែបបទនៃសេចក្តីជូនដំណឹងស្តីពី ការសម្រេចចិត្តដែលផ្តល់អោយដោយ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់។ ទំរង់បែបបទនៃសេចក្តីជូនដំណឹងអំពី ការសម្រេចចិត្តដែលបានបំពេញរួច ត្រូវតែដាក់ជូននាយកមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ។ សេចក្តីសម្រេចរបស់ មជ្ឈមណ្ឌលអភិវឌ្ឍ៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ នឹងចូលជាធរមានក្នុង**រយៈពេល ១០ ថ្ងៃ បន្ទាប់ពីការទទួលបានដោយមជ្ឈមណ្ឌល អភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ នូវសេចក្តីជូនដំណឹងស្តីពីការសម្រេចចិត្តនៃការស្នើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌ ។**

### ***តើមានអ្វីកើតឡើង ប្រសិនបើខ្ញុំមិនយល់ព្រមចំពោះសេចក្តីសម្រេចទៅលើការជួបមិនមែនជាផ្លូវការរបស់មជ្ឍមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឍមណ្ឌលប្រចាំតំបន់ ?***

ប្រសិនបើអ្នក ឬ អ្នកតំណាងស្របច្បាប់របស់អ្នក មិនពេញចិត្តនឹងសេចក្តីសម្រេចរបស់មជ្ឍមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឍមណ្ឌលប្រចាំ តំបន់ បន្ទាប់ពីការជួបមិនមែនជាផ្លូវការដោយស្ម័គ្រចិត្តទេនោះ បញ្ហានោះនឹងត្រូវបន្តទៅការសម្របសម្រួល ប្រសិនបើការសម្របសម្រួលត្រូវបាន ស្នើសុំ និង ត្រូវបានទទួលយក ហើយការស្នើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌មិនទាន់ត្រូវបានគេដកចេញទេនោះ ។ ប្រសិនបើការសម្របសម្រួល មិនទាន់ត្រូវបានស្នើសុំ ឬ ទទួលយក ហើយការស្នើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌មិនទាន់ត្រូវបានគេដកចេញដែរនោះ បញ្ហាដែលមាន នឹងត្រូវបន្ត ទៅការធ្វើសវនាការយុត្តិធម៌ ។

### ***តើការសម្របសម្រួលត្រូវបានគ្រោងធ្វើឡើងដោយរបៀបណា ?***

បន្ទាប់ពីការទទួលបាននូវសំណើជាលាយលក្ខណ៍អក្សរសុំឱ្យមានការសម្របសម្រួល មជ្ឍមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឍមណ្ឌលប្រចាំតំបន់ នឹងត្រូវបានផ្តល់ឱ្យនូវ**ថ្ងៃសម្រាប់ធ្វើការចំនួន ៥ ថ្ងៃ** ដើម្បីទទួលយក ឬ ច្រានចោលការសម្របសម្រួលនោះ ។ អ្នក តំណាងស្របច្បាប់របស់អ្នក និង Office of Administrative Hearings នឹងត្រូវបានជូនដំណឹងស្តីពីសេចក្តីសម្រេចរបស់ មជ្ឍមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឍមណ្ឌលប្រចាំតំបន់ភ្លាមៗ ។

**ក្នុងរយៈពេល ៥ថ្ងៃ នៃប្រតិទិន** បន្ទាប់ពីការទទួលបានសេចក្តីជូនដំណឹងអំពីសេចក្តីសម្រេចថាត្រូវទទួលយកការសម្របសម្រួលរបស់ មជ្ឍមណ្ឌលប្រចាំរដ្ឋ ឬ មជ្ឍមណ្ឌលប្រចាំតំបន់ Office of Administration Hearings នឹងជូនដំណឹងដល់អ្នក អ្នកតំណាងស្របច្បាប់របស់អ្នក និង មជ្ឍមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឍមណ្ឌលប្រចាំតំបន់ ស្តីពីចំណុចដូចខាងក្រោម :

- ពេលវេលា ទីកន្លែង និង កាលបរិច្ឆេទនៃការសម្របសម្រួល
- សិទ្ធិរបស់អ្នក និង សិទ្ធិរបស់មជ្ឍមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឍមណ្ឌលប្រចាំតំបន់
- ការអាចរកបាននូវជំនួយខាងការគាំទ្រ
- ឈ្មោះ អាស័យដ្ឋាន និង លេខទូរស័ព្ទរបស់បុគ្គល ឬ ការិយាល័យដែលនឹងត្រូវសម្របសម្រួលជម្លោះនោះ ។

ការសម្របសម្រួល នឹងត្រូវធ្វើឡើង**ក្នុងរយៈពេល ៣០ ថ្ងៃ** គិតតាំងពីថ្ងៃដែលបែបបទនៃការស្នើសុំឱ្យមានការធ្វើសវនាការ យុត្តិធម៌ ត្រូវបានទទួលដោយមជ្ឍមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឍមណ្ឌលប្រចាំតំបន់ ។

### ***តើត្រូវធ្វើដូចម្តេច ប្រសិនបើខ្ញុំត្រូវការឱ្យគេគ្រោងធ្វើការសម្របសម្រួលសារជាថ្មី ?***

អ្នកអាចស្នើសុំឱ្យមានការពន្យាពេលនៃការសម្របសម្រួល ។ សំណើរបស់អ្នក អាចនឹងត្រូវផ្តល់ជូនទៅតាមសេចក្តីសម្រេចចិត្តរបស់អ្នកសម្រប សម្រួល ។ ប្រសិនបើសំណើសុំឱ្យពន្យាពេលនៃការសម្របសម្រួល ត្រូវបានគេផ្តល់ជូន ការប្រជុំនៃការសម្របសម្រួលនឹងត្រូវបានគេគ្រោងធ្វើ សារជាថ្មី ហើយពេលវេលានៃការចេញសេចក្តីសម្រេចធ្វើសវនាការយុត្តិធម៌ អាចនឹងត្រូវបានពន្យា ។

### ***តើការសម្របសម្រួលមានលក្ខណៈយ៉ាងដូចម្តេច ?***

ការសម្របសម្រួលគឺជាការជួបដោយស្ម័គ្រចិត្តមួយ នៃភាគីណាដែលមានជម្លោះជាមួយបុគ្គលអព្យាក្រិត្យម្នាក់ (អ្នកសម្របសម្រួល) ដែលមានការបណ្តុះបណ្តាល និង បទពិសោធន៍ក្នុងការជួយមនុស្សដើម្បីដោះស្រាយជម្លោះ ។ វាគឺជាយុទ្ធសាស្ត្រសាមញ្ញមួយ សម្រាប់ដោះស្រាយជម្លោះ ដោយក្តីរាប់អាន និង ត្រូវបានប្រើជាញឹកញាប់ក្នុងវិស័យជាច្រើន ។ អ្នកសម្របសម្រួលផ្តល់ភាពងាយស្រួល ដល់ការជួបប្រជុំ ដែលមិនមានការប្រឆាំង និង មិនមែនជាផ្លូវការ ដែលភាគីទាំងនោះមានឱកាស និង សិទ្ធិដើម្បីទទួលយកសេចក្តីសម្រេចមួយ ។ អ្នកសម្របសម្រួលជួយដល់ភាគីទាំងអស់ ដើម្បីពិចារណាពីការពិត បញ្ហាទាំងឡាយ និង ហេតុផលទាំងឡាយចំពោះការប្តឹងតវ៉ា និង ចំពោះសេចក្តីសម្រេចរបស់មជ្ឍមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឍមណ្ឌលប្រចាំតំបន់ ហើយនិងជួយភាគីទាំងអស់ជាមួយនឹងគោលបំណង នៃការឈានទៅរកដំណោះស្រាយមួយដែលអាចទទួលយកបានដោយភាគីទាំងពីរ ។

ក្នុងអំឡុងពេលសម្របសម្រួល អ្នកសម្របសម្រួលអាចនឹងជួបដោយឡែកពីគ្នា និង ដោយសម្ងាត់ជាមួយនឹងបុគ្គលណាម្នាក់ ឬ ក្រុម អ្នកដែលពាក់ព័ន្ធក្នុងការសម្របសម្រួលនេះ ។ ការធ្វើបែបនេះ ពេលខ្លះគេហៅថា ˝ ការជួបប្រជុំដើម្បីសម្រេចគោលបំណងអ្វីមួយ ˝ ។ ដោយសារតែអ្នកសម្របសម្រួល មិនធ្វើដូចជាចៅក្រម ទើបបញ្ហាទាំងឡាយដែលមានការប្រកែកប្រណាំងគ្នា ត្រូវបានដោះស្រាយតាមរយៈការ សម្របសម្រួលតែនៅពេលដែលភាគីទាំងពីរឈានដល់ការព្រមព្រៀងមួយ ដែលអាចទទួលយកបានដោយភាគីទាំងសងខាងតែប៉ុណ្ណោះ ។ ដោយសារតែការសម្របសម្រួលគឺជាការស្ម័គ្រចិត្ត ទើបអ្នក អ្នកតំណាងស្របច្បាប់របស់អ្នក ឬ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌល ប្រចាំតំបន់ អាចនឹងសម្រេចចិត្តនៅពេលណាក៏បានដើម្បីបន្តទៅការធ្វើសវនាការ ដោយមិនចាំបាច់មានការសម្របសម្រួល ។ អ្នកសម្របសម្រួល នឹងត្រូវផ្តល់ជូនដោយ Office of Administration Hearings ។ ការសម្របសម្រួលនោះ នឹងត្រូវធ្វើឡើងជាភាសាអង់គ្លេស ប៉ុន្តែ Office of Administration Hearings នឹងផ្តល់ជូននូវអ្នកបកប្រែម្នាក់ ប្រសិនបើចាំបាច់ ហើយប្រសិនបើ ត្រូវបានស្នើសុំមុនការសម្របសម្រួល ។

ប្រសិនបើការព្រមព្រៀងមួយត្រូវបានឈានដល់ តាមរយៈការសម្របសម្រួល ហើយអ្នកលែងប្រាថ្នាបន្តទៅធ្វើសវនាការទេនោះ អ្នកត្រូវតែបំពេញបែបបទនៃសេចក្តីជូនដំណឹងស្តីពីការសម្រេចចិត្ត ដែលបានផ្តល់ជូនដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ដោយអ្នកសម្របសម្រួល និង ដោយមជ្ឈមណ្ឌលប្រចាំតំបន់ ។ បែបបទនៃសេចក្តីជូនដំណឹងស្តីពីការសម្រេចចិត្ត ដែលបានបំពេញរួច ត្រូវតែដាក់ជូននាយកមជ្ឈមណ្ឌល អភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ។ សេចក្តីសម្រេចចុងក្រោយដែលត្រូវបានព្រមព្រៀងក្នុងអំឡុងពេលការសម្របសម្រួល និង ចូលជាធរមាន **ក្នុងរយៈពេល ១០ ថ្ងៃ បន្ទាប់ពីការទទួលដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ នូវសេចក្តីជូនដំណឹង ស្តីពីការសម្រេចនៃសំណើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌** ។

### *តើមានអ្វីកើតឡើង ប្រសិនបើការសម្របសម្រួល មិនអាចដោះស្រាយបញ្ហាបាន?*

ប្រសិនបើការសម្របសម្រួល មិនបានដោះស្រាយបញ្ហាបាន ទៅតាមការពេញចិត្តរបស់អ្នក ឬ ទៅតាមការពេញចិត្តរបស់តំណាងស្រប ច្បាប់របស់អ្នក បញ្ហាមួយ ឬ ច្រើនដែលមិនទាន់បានដោះស្រាយនោះ នឹងបន្តទៅការធ្វើសវនាការយុត្តិធម៌ ។ អ្នកសម្របសម្រួល នឹងផ្តល់ដំណឹងភ្លាម ដល់ការិយាល័យសវនាការខាងកិច្ចការរដ្ឋបាល ស្តីពីលទ្ធផលនៃការសម្របសម្រួល ។

### *តើការធ្វើសវនាការយុត្តិធម៌ ត្រូវបានគ្រោងធ្វើឡើងដោយរបៀបណា ?*

នៅពេលការស្នើសុំឱ្យមានការធ្វើសវនាការត្រូវបានគេទទួល ការិយាល័យសវនាការខាងកិច្ចការរដ្ឋបាល នឹងផ្តល់ដំណឹងភ្លាមដល់អ្នក អ្នកតំណាង ស្របច្បាប់របស់អ្នក និង នាយកមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ជាលាយលក្ខណ៍អក្សរស្តីពីចំណុចដូចខាងក្រោម :

- ពេលវេលា ទីកន្លែង និង កាលបរិច្ឆេទនៃការធ្វើសវនាការយុត្តិធម៌
- សិទ្ធិរបស់អ្នក ដែលរួមទាំងចំណុចដទៃទៀតដែលត្រូវបានកំណត់ក្នុងទំព័រទី ៣ នៃកូនសៀវភៅតូចនេះ ហើយនិងសិទ្ធិរបស់មជ្ឈមណ្ឌល អភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់
- ការអាចរកបាននូវជំនួយខាងការគាំទ្រ និង
- ឈ្មោះ អាស័យដ្ឋាន និង លេខទូរស័ព្ទរបស់បុគ្គល ឬ ការិយាល័យដែលនឹងត្រូវធ្វើសវនាការយុត្តិធម៌នោះ។

ការធ្វើសវនាការយុត្តិធម៌ នឹងត្រូវធ្វើឡើងក្នុង**រយៈពេល ៥០ ថ្ងៃ** បន្ទាប់ពីថ្ងៃ ដែលបែបបទការស្នើសុំឱ្យមានការធ្វើសវនាការ យុត្តិធម៌នោះ ត្រូវបានទទួលដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ។ អ្នក អ្នកតំណាងស្របច្បាប់របស់អ្នក ឬ មជ្ឈមណ្ឌល អភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ អាចនឹងស្នើសុំពេលវេលាបន្ថែម ។ សេចក្តីសម្រេចខាងកិច្ចការរដ្ឋបាលចុងក្រោយ ត្រូវតែចេញក្នុង **រយៈពេល ៩០ ថ្ងៃ** នៃការទទួលសំណើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌ដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ។

### *តើត្រូវធ្វើដូចម្តេច ប្រសិនបើខ្ញុំត្រូវការឱ្យគេគ្រោងធ្វើសវនាការយុត្តិធម៌សារជាថ្មី ?*

អ្នកអាចនឹងស្នើសុំឱ្យមានការពន្យាពេលនៃការធ្វើសវនាការ ដោយមូលហេតុសមរម្យ ។ ចៅក្រមច្បាប់រដ្ឋបាល នឹងសម្រេចថាតើសំណើរបស់អ្នក គួរតែត្រូវបានផ្តល់ជូន ឬ អត់ ។

ប្រសិនបើសំណើសុំពន្យាពេលរបស់អ្នកត្រូវបានគេផ្តល់ជូន ការធ្វើសវនាការនឹងត្រូវបានគេគ្រោងធ្វើសារជាថ្មី ហើយពេលវេលាដែលត្រូវបានអនុញ្ញាតឱ្យចំពោះការចេញសេចក្តីសម្រេចអាចនឹងត្រូវពន្យាពេលផងដែរ ។ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ក៏នឹងអាចស្នើសុំអោយមានការពន្យាពេលសវនាការយុត្តធមិផងដែរ។ ការពន្យាពេលដែលត្រូវបានផ្តល់ឱ្យ តាមសំណើ របស់មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ អាចនឹងមិនពន្យាពេលឱ្យចៅក្រមច្បាប់រដ្ឋបាល ដើម្បីចេញសេចក្តីសម្រេចទេ ។

ការធ្វើសវនាការយុត្តិធមិ នឹងត្រូវធ្វើឡើងនៅពេលវេលា និង ទីកន្លែងណាមួយដែលងាយស្រួលយ៉ាងសមរម្យ សម្រាប់អ្នក និង តំណាង ស្របច្បាប់របស់អ្នក ។ អ្នក អ្នកតំណាងស្របច្បាប់របស់អ្នក និង មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ត្រូវតែទទួលយកទីតាំងនៃ ការធ្វើសវនាការយុត្តិធមិនោះ ។ ការធ្វើសវនាការយុត្តិធមិនឹងត្រូវធ្វើឡើងជាភាសាអង់គ្លេស ។ អ្នកបកប្រែម្នាក់ នឹងត្រូវបានផ្តល់ជូនដោយ ការិយាល័យសវនាការខាងកិច្ចការរដ្ឋបាល ប្រសិនបើចាំបាច់ និង ប្រសិនបើត្រូវបានស្នើសុំជាមុន ។

## *តើសវនាការយុត្តិធមិមានលក្ខណៈយ៉ាងដូចម្តេច ?*

សវនាការយុត្តិធមិ អាចនឹងស្រដៀងគ្នានឹងសវនាការតុលាការដែលមានសាក្សី ការបង្ហាញ និង ការត្រួតពិនិត្យលើភស្តុតាង ។ សវនាការយុត្តិធមិមិនចាំបាច់ត្រូវធ្វើឡើងឱ្យស្របទៅតាមការត្រួតពិនិត្យផ្នែកបច្ចេកទេសទៅលើភស្តុតាង ហើយចំណុចផ្សេងទៀតដែលទាក់ទងនឹងសាក្សីនោះទេ ។ចៅក្រមច្បាប់រដ្ឋបាលនឹងធ្វើជាប្រធាន ។ ចៅក្រមនោះមិនត្រូវបានជួលដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ទេ តែត្រូវបានជួលដោយការិយាល័យសវនាការខាងកិច្ចការរដ្ឋបាល ។

នៅពេលធ្វើសវនាការយុត្តិធមិ អ្នកអាចនឹងត្រូវជាតំណាងដោយខ្លួនឯង ។ អ្នកក៏អាចនឹងត្រូវបានធ្វើជាតំណាងដោយមេធាវី អ្នកគាំទ្រ សមាជិកគ្រួសារ មិត្តភក្តិ ឬ អ្នកណាម្នាក់ផ្សេងទៀតដែលអ្នកជ្រើសរើស ។ ប្រសិនបើអ្នកជួលមេធាវីម្នាក់ ឬ អ្នកណាម្នាក់ផ្សេងទៀត អ្នកនឹងត្រូវ ទទួលខុសត្រូវចំពោះចំណាយទាំងនោះ ។ បុគ្គលិកផ្នែកគ្រប់គ្រង និង អ្នករៀបចំម្នាក់ ជាធម្មតាធ្វើជាតំណាងឱ្យមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ។

**យ៉ាងហោចណាស់ក្នុងរយៈពេល ៥ ថ្ងៃ មុនពេលធ្វើសវនាការយុត្តិធមិ អ្នក និង មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ ត្រូវតែដោះដូរគ្នានូវបញ្ជីឈ្មោះរបស់សាក្សីទាំងអស់ កម្មវត្ថុនៃកសិណសាក្សីរបស់សាក្សីនិមួយៗ ព្រមទាំងអត្ថបទថតចម្លងនៃភស្តុតាង ជាឯកសារ ទាំងអស់ ដែលនឹងអាចមាន ។ ប្រសិនបើពត៌មានផ្សេងៗ មិនត្រូវបានផ្តល់ជូនជាមុន ចៅក្រមច្បាប់រដ្ឋបាល អាចនឹងមិនអនុញ្ញាតឱ្យគេប្រើវានៅ ពេលធ្វើសវនាការនោះទេ ។** ប្រសិនបើអ្នកមិនយល់ពីពត៌មានដែលអ្នកទទួលបាន អ្នកអាចស្នើសុំជំនួយពីអ្នកគាំទ្រណាម្នាក់ ។

ភាគីទាំងសងខាងអាចផ្តល់ភស្តុតាងដែលទាក់ទង ដើម្បីបញ្ជាក់ការពិតទៅលើរឿងក្តីរបស់ខ្លួន ។ ភាគីទាំងពីរ អាចនាំសាក្សីណាដែលដឹង ពីបញ្ហាដែលទាក់ទង និង ឯកសារផ្សេងៗទៀត ដូចជារបាយការណ៍ស្តីពីសេវាកម្ម ឬ សេចក្តីរាយការណ៍ផ្នែកវេជ្ជសាស្ត្រ ។ អ្នកគួរតែព្យាយាម ឱ្យសាក្សីមកដោយស្ម័គ្រចិត្ត ប៉ុន្តែអ្នកមានសិទ្ធិដើម្បីទាមទាររបាយការណ៍ដែលពាក់ព័ន្ធ ឬ កោះហៅមនុស្សឱ្យចូលរួមក្នុងការធ្វើសវនាការយុត្តធមិ នេះបាន។ ប្រសិនបើអ្នកកោះហៅសាក្សីឱ្យចូលរួមក្នុងសវនាការ នោះប្រហែលជានឹងមានការចំណាយមួយចំនួន ហើយ/ឬ ប្រាក់មួយចំនួន ដែលនឹងជាការទទួលខុសត្រូវរបស់អ្នក ។ **សូមទាក់ទងការិយាល័យសវនាការខាងកិច្ចការរដ្ឋបាលឱ្យបានល្អ មុនពេលការធ្វើសវនាការយុត្តិធមិ ដើម្បីទទួលបាននូវលិខិតកោះហៅទាំងនោះ** ។ រាល់កសិណសាក្សីទាំងអស់ នឹងត្រូវមានការស្បថ ឬ ការអះអាងបញ្ជាក់ ។ **មុនពេលដែលសវនាការយុត្តិធមិបិទ ភាគីរបស់អ្នកត្រូវដាក់ជូនរាល់ភស្តុតាងដែលអ្នកចង់ឱ្យចៅក្រមច្បាប់រដ្ឋបាលពិចារណា** ។ បន្ទាប់ពីកសិណសាក្សីទាំងអស់ត្រូវបានទទួលដឹងឮ ភាគីទាំងសងខាង អាចនឹងធ្វើការប្រកែកប្រណាំងគ្នាបញ្ចប់ ដែលលើកឡើងពីការពិត ដែលទទួលបានពីភស្តុតាងផ្សេងៗ ។

## *តើខ្ញុំនឹងត្រូវបានគេផ្តល់ដំណឹងពីសេចក្តីសម្រេចនៃការធ្វើសវនាការយុត្តិធមិដោយវិធីណា និង នៅពេលណា ?*

សេចក្តីសម្រេចរបស់ចៅក្រមរដ្ឋបាល នឹងរួមមាន :

- សេចក្តីសង្ខេបពីការពិតមួយ

- របាយការណ៍នៃភស្តុតាងដែលត្រូវបានផ្អែកលើ
- សេចក្តីសម្រេចទៅលើបញ្ហានីមួយៗ
- ការកំណត់ច្បាប់ បទបញ្ញត្តិ និង គោលនយោបាយផ្សេងៗដែលគាំទ្រសេចក្តីសម្រេច
- ការជូនដំណឹងថានេះ គឺជាសេចក្តីសម្រេចនៃសវនាការខាងកិច្ចការរដ្ឋបាលចុងក្រោយ និង
- ការជូនដំណឹងថា អ្នក ឬ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់អាចនឹងប្តឹងទៅតុលាការដែលមានយុត្តាធិការមានប្រសិទ្ធភាព ក្នុង**រយៈពេល ៩០ ថ្ងៃ** ។

ប្រសិនបើបញ្ហាទាំងឡាយដែលបានលើកឡើងក្នុងសវនាការ **មិនទាក់ទងនឹង Waiver Program** ទេនោះ ចៅក្រមច្បាប់រដ្ឋបាលនឹងផ្ញើសេចក្តីសម្រេចជាលាយលក្ខណ៍អក្សរទៅឱ្យអ្នក អ្នកតំណាងស្របច្បាប់របស់អ្នក និង មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌល ប្រចាំតំបន់ក្នុង**រយៈពេល ១០ ថ្ងៃ** បន្ទាប់ពីថ្ងៃចុងក្រោយនៃការធ្វើសវនាការយុត្តិធម៌ ប៉ុន្តែមិនឱ្យយឺតជាង **៨០ ថ្ងៃ** បន្ទាប់ពីកាលបរិច្ឆេទ ដែលបែបបទនៃការស្នើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌ត្រូវបានទទួលដោយមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់នោះទេ ។

ប្រសិនបើបញ្ហាទាំងឡាយដែលបានលើកឡើងនៅក្នុងសវនាការ**ពិត**ជាទាក់ទងនឹង Waiver Program អ្នកនឹងទទួលបាននូវសេចក្តីសម្រេច ចុងក្រោយ ក្នុង**រយៈពេល ៩០ ថ្ងៃ** បន្ទាប់ពីកាលបរិច្ឆេទដែលបែបបទនៃការស្នើសុំឱ្យមានការធ្វើសវនាការយុត្តិធម៌ត្រូវបានបោះត្រាលើ ឬ ទទួលបានដោយ មជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ មជ្ឈមណ្ឌលប្រចាំតំបន់ណាមួយដែលទទួលបានលឿនជាង ។

ប្រសិនបើសេចក្តីសម្រេចនេះ មិនពេញចិត្តអ្នក ហើយអ្នកបាននឹងកំពុងទទួលនូវសេវាកម្មផ្សេងៗទៀត ដែលមានការទាក់ទងនឹងការ ប្តឹងសេចក្តីសម្រេចនោះនឹងមិនត្រូវបានយកមកអនុវត្តរហូតដល់ **១០ ថ្ងៃ** បន្ទាប់ពីអ្នក និង អ្នកតំណាងស្របច្បាប់របស់អ្នក ទទួលបាននូវសេចក្តីសម្រេច តាមរយៈសំបុត្រដោយផ្ទាល់ ។ ប្រសិនបើអ្នក ឬ អ្នកតំណាងស្របច្បាប់របស់អ្នក មិនអាចយល់ភាសាអង់គ្លេសបាន សេចក្តីសម្រេចនឹង ត្រូវផ្តល់ជូនជាភាសាអង់គ្លេស និង ភាសាដែលអ្នក ឬ អ្នកតំណាងស្របច្បាប់របស់អ្នកយល់ ។

### ***តើច្បាប់ និង បទបញ្ញត្តិអ្វីខ្លះ ដែលមាននៅក្នុងនីតិវិធីនៃការធ្វើសវនាការយុត្តិធម៌ ?***

ចំណងជើងលេខ ១៧ នៃច្បាប់ស្តីពីបទបញ្ញត្តិរបស់រដ្ឋកាលីហ្វ័រញ៉ា សុខភាពសាធារណៈ ផ្នែកទី ២ ជំពូកទី ១ ជំពូករងទី ៩ និង ច្បាប់ស្តីពីការផ្តល់សេវាកម្មដល់ភាពអសមត្ថភាពក្នុងការអភិវឌ្ឍន៍ Lanterman (ច្បាប់ស្តីពីទំនៀមទំលាប់ និង សុខុមាលភាព ផ្នែកទី ៤.៥ ជំពូកទី ៧ មាត្រាទី ៤៧០០ - ៤៧៣០) ។

សម្រាប់ព័ត៌មានបន្ថែម
សូមទំនាក់ទំនងមកមជ្ឈមណ្ឌលអភិវឌ្ឍន៍ប្រចាំរដ្ឋ ឬ
មជ្ឈមណ្ឌលប្រចាំតំបន់របស់អ្នក